# ការថ្វាយបង្គំ

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

## សេចក្ដីផ្ដើម

«ការថ្វាយបង្គំ» ប្រហែលជាពាក្យដែលពួកគ្រីស្ទបរិស័ទសព្វថ្ងៃប្រើខុសច្រើនបំផុត។ ជារឿយៗនៅ ពេលពួកគ្រីស្ទបរិស័ទប្រើពាក្យការថ្វាយបង្គំ ពួកគេសំដៅទៅលើការច្រៀង។ នៅក្នុងកម្មវិធីរបស់ពួកជំនុំ ជារឿយៗពួកគ្រីស្ទបរិស័ទនិយាយថា នៅពេលយើងចាប់ផ្ដើមច្រៀង នោះយើងកំពុងចូលទៅក្នុងពេលវេលាថ្វាយបង្គំហើយ។ ជារឿយៗនៅពេលពួកគ្រីស្ទបរិស័ទប្រើពាក្យ «អ្នកដឹកនាំថ្វាយបង្គំ» ពួកគេកំពុងសំដៅទៅលើមនុស្សដែលដឹកនាំការច្រៀង។ ការគិតដូច្នេះគឺធម្មតានៅក្នុងបណ្ដាប្រទេសដែលនិយាយភាសាអង់គ្លេស និងពួកបេសកជនដែលនិយាយភាសាអង់គ្លេសបាននាំការគិតដូចនេះមកកាន់ប្រទេសកម្ពុជា។ ប៉ុន្តែព្រះគម្ពីរបង្ហាញថា ការគិតដូចនេះពិតជាខុសទាំងស្រុង។

## អ្វីដែលព្រះគម្ពីរបង្រៀនអំពីការថ្វាយបង្គំ

ព្រះយេស៊ូវមានបន្ទូលនៅក្នុងយ៉ូហាន ៤:២៣ ថា «នឹងមានពេលវេលាមក ក៏នៅតែឡូវនេះហើយ នោះពួកអ្នកដែលថ្វាយបង្គំដោយពិតត្រង់ គេនឹងថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ និងសេចក្ដីពិត ពីព្រោះព្រះវរបិតាទ្រង់រកពួកអ្នកយ៉ាងនោះ ឱ្យបានថ្វាយបង្គំទ្រង់»។ ច្បាស់ណាស់ នៅពេលព្រះយេស៊ូវមានបន្ទូលអំពី «គេនឹងថ្វាយបង្គំព្រះវរបិតាដោយវិញ្ញាណ និងសេចក្ដីពិត» ទ្រង់មិនកំពុងសំដៅទៅលើសកម្មភាពច្រៀងនោះឡើយ។ នៅពេលព្រះយេស៊ូវដកស្រង់ព្រះគម្ពីរសញ្ញាចាស់ «គេថ្វាយបង្គំអញជាឥតប្រយោជន៍ទេ ព្រោះគេបង្រៀនសេចក្ដីដែលជាបញ្ញត្តរបស់មនុស្សវិញ» (ម៉ាថាយ ១៥:៩; ម៉ាកុស ៧:៧) ទ្រង់មិនកំពុងសំដៅលើការច្រៀងជាឥតប្រយោជន៍នោះទេ។ នៅពេលយ៉ូហាន ៩:៣៨ និយាយថា «គាត់ទូលថា "ខ្ញុំជឿហើយ ព្រះអម្ចាស់អើយ រួចគាត់ក៏ក្រាបថ្វាយបង្គំទ្រង់"» វាមិនមានន័យថា គាត់បានចាប់ផ្ដើមច្រៀងដោយខ្លួនឯង នៅមុខព្រះយេស៊ូវនោះទេ។ លោកប៉ុលសរសេរនៅក្នុងរ៉ូម ១២:១ ថា យើងគួរតែថ្វាយរូបកាយរបស់យើងជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ដែលនេះគឺជាសកម្មភាពខាងវិញ្ញាណក្នុងការថ្វាយបង្គំ។ នៅទីនេះ សកម្មភាពថ្វាយបង្គំរបស់យើងមិនមែនជាការច្រៀងទេ ប៉ុន្តែជាការថ្វាយជីវិតរបស់យើងទៅចំពោះព្រះវិញ។ នេះមិនមានន័យថា ការច្រៀងមិនមែនជាការថ្វាយបង្គំនោះទេ។ ការច្រៀងគឺជាការថ្វាយបង្គំ ប៉ុន្តែរបៀបដែលយើងប្រើពាក្យនៅសព្វថ្ងៃនេះអាចមានគ្រោះថ្នាក់។ ដូច្នេះ តើព្រះគម្ពីរបង្រៀនអ្វីអំពីការថ្វាយបង្គំ?

## ពាក្យក្នុងព្រះគម្ពីរសំរាប់ការថ្វាយបង្គំ

តើពាក្យ*ថ្វាយបង្គំ*មានន័យដូចម្ដេច? តើពាក្យ*គោរព*មានន័យដូចម្ដេច? តើពាក្យ*បំរើ*មានន័យដូចម្ដេច? ជាធម្មតានៅពេលយើងសួរសំនួរនេះដល់ជនជាតិខ្មែរ ពួកគេនិយាយថា ពាក្យទាំងនេះមានអត្ថន័យខុសគ្នាខ្លាំងណាស់ ជាពិសេសពាក្យ*ថ្វាយបង្គំ* និង*បំរើ*។ ប៉ុន្តែពាក្យទាំងនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងព្រះគម្ពីរ។ ពាក្យភាសាហេព្រើរ និងភាសាក្រិកមានន័យត្រួតលើគ្នា។ សូមប្រៀបធៀបការបកប្រែជាភាសាខ្មែរលើនិក្ខមនំ ៨:១ «ចូរបើកឱ្យរាស្ត្រអញចេញទៅ*ថ្វាយ*

*បង្គំ*អញ» (ព្រះគម្ពីរខ្មែរបរិសុទ្ធ) «ចូរបើកអោយប្រជារាស្ត្ររបស់យើងចេញទៅ*គោរពបំរើ*យើង» (គខប)។ តើហេតុអ្វីបានជាការបកប្រែមួយ បកប្រែពាក្យហេព្រើរ עבד ដោយការប្រើពាក្យ*ថ្វាយបង្គំ* ហើយការបកប្រែមួយទៀត បកប្រែពាក្យហេព្រើរនេះជាពាក្យ *គោរពបំរើ* ទៅវិញ? ការបកប្រែជាភាសាអង់គ្លេសបកប្រែដូចនេះដែរ។ ការបកប្រែខ្លះបកប្រែជា «ការថ្វាយបង្គំ» (worship) ហើយខ្លះទៀតបកប្រែជា «បំរើ» (serve)។ នេះដោយសារតែយើងអាចបកប្រែពាក្យ עבד ជាពាក្យទាំងពីរខាងលើ (*ថ្វាយបង្គំ* ឬ *បម្រើ*) ប៉ុន្តែអត្ថន័យគ្រឹះគឺ បម្រើ ហើយជាទូទៅពាក្យហេព្រើរត្រូវគេបកប្រែជា «បំរើ» ឬជាមួយពាក្យដែលទាក់ទងនឹង «បំរើ» នៅក្នុងព្រះគម្ពីរសញ្ញាចាស់។ វាជាពាក្យដដែលដែលគេបានប្រើដើម្បីបរិយាយអំពីអ៊ីស្រាអែល «បំរើ» ស្ដេចផារ៉ោន (និក្ខមនំ ១:១៤)។ ដូច្នេះ ស្ដេចផារ៉ោនត្រូវតែដោះលែងរាស្ត្ររបស់ព្រះ ដើម្បីពួកគេអាចឈប់បំរើស្ដេចផារ៉ោនហើយបម្រើព្រះវិញ។ បើអញ្ចឹង តើហេតុអ្វីបានជាការបកប្រែខ្លះបកប្រែពាក្យនេះជា «ថ្វាយបង្គំ»? ពីព្រោះបើយោងតាមព្រះគម្ពីរ របៀបគន្លឹះដែលយើងថ្វាយបង្គំព្រះគឺដោយការបំរើទ្រង់។ នៅពេលយើងបំរើទ្រង់ នោះយើងកំពុងថ្វាយបង្គំទ្រង់ ហើយប្រសិនបើយើងមិនបំរើទ្រង់នៅក្នុងជីវិតរបស់យើងទេ នោះយើងមិនកំពុងថ្វាយបង្គំទ្រង់នោះទេ។ ពាក្យហេព្រើរមួយទៀតសំរាប់ការថ្វាយបង្គំ (*hištaḥ$^{a}$wâ*) មានន័យថា ឱនចុះត្រឹមចង្កេះ ហើយមានអត្ថន័យគ្រឹះជា ការឱនចុះដោយការគោរព ឬថ្វាយបង្គំ (ឧទាហរណ៍ លោកុប្បត្តិ ២៤:២៦, ៤៨) ដូចជាជនជាតិខ្មែរធ្វើចំពោះមហាក្សត្ររបស់ពួកគេផងដែរ។

យើងអាចមើលឃើញអត្ថន័យទាំងនេះផងដែរ ដោយមើលទៅលើពាក្យភាសាក្រិកដែលត្រូវបានបកប្រែជា «ថ្វាយបង្គំ»។ ពាក្យក្រិកគន្លឹះសំរាប់ការថ្វាយបង្គំគឺ *latreia* (នាម) ដែលមានន័យថា ការបំរើ service (ministry)។ (ឧទាហរណ៍ រ៉ូម ១:៩) និង *latreuō* (កិរិយាស័ព្ទ) ដែលមានន័យថា បំរើ និង *proskyneō* (កិរិយាស័ព្ទ)។ ពាក្យមួយទៀតដែលមិនសូវត្រូវបានគេប្រើគឺ *sebō*។

## តើការថ្វាយបង្គំគឺជាអ្វី?

វាជាការសំខាន់ក្នុងការមើលលើពាក្យ និងខគម្ពីរទាំងនេះដែលមានខាងលើ ពីព្រោះគ្មានកន្លែងណានៅក្នុងព្រះគម្ពីរបានផ្ដល់អត្ថន័យលើការថ្វាយបង្គំនោះទេ។ ប៉ុន្តែនៅពេលយើងពិនិត្យពាក្យសំរាប់ការថ្វាយបង្គំតាមព្រះគម្ពីរនៅក្នុងបរិបទផ្សេងៗ នោះនាំឲ្យយើងមើលឃើញច្បាស់ថា អត្ថន័យចំបងគឺជា ការគោរព ការបំរើ និងការកោតខ្លាច។[1] មាននិយមន័យមួយចំនួនសំរាប់ការថ្វាយបង្គំ រួមទាំងការគោរពដែលត្រូវថ្វាយដល់ព្រះ ដែលវាជាអំពើបាប (ការថ្វាយបង្គំរូបព្រះ) បើសិនយើងថ្វាយការគោរពនោះទៅដល់ស្នាព្រះហស្តណាមួយនោះ។[2] ការកោតខ្លាចនៅចំពោះវត្តមានដ៏ធំថ្កើងរបស់ព្រះអម្ចាស់។[3] ការបង្ហាញការកោតខ្លាច និងការសរសើរតម្កើងដល់ព្រះ។ ការថ្វាយបង្គំមានទាំងសកម្មភាពដូចជា ការសរសើរតម្កើង ការអរព្រះគុណ ការបំរើព្រះ សេចក្ដីអធិស្ឋាន ការថ្វាយយញ្ញបូជា និងសម្បថ។

## យើងគួរតែថ្វាយបង្គំព្រះ ពីព្រោះទ្រង់សមនឹងទទួលការថ្វាយបង្គំ

យើងគួរតែថ្វាយបង្គំព្រះ ពីព្រោះទ្រង់សមនឹងទទួលការថ្វាយបង្គំនិងការសរសើរតម្កើង (២សាំយ៉ូអែល ២២:៤; ១របាក្សត្រ ១៦:២៥; ទំនុកដំកើង ១៨:៣; ៤៨:១; ៩៦:៤; ១៤៥:៣; វិវរណៈ ៥:១២)។ ការថ្វាយបង្គំរូបព្រះគឺជាការអាក្រក់ហើយល្ងីល្ងើ ពីព្រោះយើងថ្វាយបង្គំរបស់ដែលមិនសមនឹងទទួលការថ្វាយបង្គំ។ ពាក្យភាសាអង់គ្លេស *worship* មកពី ពាក្យ *សមនឹងទទួលបាន* *worthy* ។ (ភាសាអង់គ្លេសចាស់ «weorthscipe»=«worth-ship») ដែលមានន័យដើមជាសកម្មភាពរបស់មនុស្សជាតិក្នុងការបង្ហាញការគោរពដល់ព្រះ ពីព្រោះទ្រង់សមនឹងទទួលការគោរពនោះ។[4]

## ការថ្វាយបង្គំពិតប្រាកដ គឺជាឆ្លើយតបចំពោះព្រះដែលបើកសម្តែងអង្គទ្រង់

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជនជាតិអ៊ីស្រាអែលគឺជាអ្នកថ្វាយបង្គំដ៏/ពិតប្រាកដរបស់ព្រះ ហើយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ពួកគ្រីស្ទបរិស័ទគឺជាអ្នកថ្វាយបង្គំដ៏ពិតប្រាកដរបស់ព្រះ។ ហេតុអ្វី? ពីព្រោះនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ជនជាតិអ៊ីស្រាអែលគឺជាមនុស្សដែលថ្វាយបង្គំព្រះដ៏ពិត ហើយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាពួកគ្រីស្ទបរិស័ទដែលថ្វាយបង្គំព្រះដ៏ពិតវិញ។ តើហេតុអ្វីក្រុមទាំងនេះគឺជាមនុស្សដែលថ្វាយបង្គំព្រះដ៏ពិត? ពីព្រោះពួកគេគឺជាមនុស្សដែលព្រះបានបើកសំដែងអង្គទ្រង់ទៅកាន់ តាមរយៈព្រះបន្ទូល និងសកម្មភាពរបស់ទ្រង់ធ្វើការជាមួយគ្នា។ អ៊ីស្រាអែល បានទទួលបានព្រះបន្ទូលរបស់ព្រះ ហេតុនេះហើយបានជាពួកគេវិសេសជាងពួកសាសន៍ដទៃ (រ៉ូម ៣:១-២)។ ដោយសារតែអ៊ីស្រាអែល បានទទួលព្រះបន្ទូលរបស់ព្រះ នោះពួកគេបានស្គាល់ព្រះដ៏ពិត ហើយអាចថ្វាយបង្គំទ្រង់បាន។ ពួកសាសន៍ដទៃមិនបានទទួលព្រះបន្ទូលរបស់ព្រះ ដូច្នេះពួកគេមិនបានស្គាល់ព្រះហើយថ្វាយបង្គំរូបព្រះវិញ (រ៉ូម ១:១៨-៣២)។ ប៉ុន្តែ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ព្រះគ្រីស្ទគឺជាព្រះបន្ទូលរបស់ព្រះ ដំណឹងល្អគឺជាព្រះបន្ទូលរបស់ព្រះ ដូច្នេះអស់អ្នកដែលទទួលដំណឹងល្អរបស់ព្រះគ្រីស្ទអាចថ្វាយបង្គំព្រះដ៏ពិតបានហើយ។

**ការអនុវត្តៈ** យើងចាំបាច់ត្រូវប្រកាសព្រះបន្ទូលរបស់ព្រះ ដែលជាដំណឹងល្អរបស់ព្រះគ្រីស្ទ ទៅកាន់មនុស្ស ដើម្បីឲ្យពួកគេអាចថ្វាយបង្គំព្រះដ៏ពិតបាន។ ប៉ុន្តែ ការថ្វាយបង្គំពិតប្រាកដមិនគ្រាន់តែជាការថ្វាយបង្គំព្រះដ៏ពិតនោះទេ ប៉ុន្តែជាការថ្វាយបង្គំព្រះដ៏ពិតតាមរបៀបដែលព្រះសព្វព្រះហឫទ័យ។ ការថ្វាយបង្គំបែបនេះនាំទៅដល់ចំនុចបន្ទាប់មកទៀត។

## ការថ្វាយបង្គំដ៏ពិតប្រាកដគឺជាការថ្វាយបង្គំដែលផ្គាប់ព្រះហឫទ័យព្រះ

ជារឿយៗពួកគ្រីស្ទបរិស័ទគ្រាន់តែគិតថា ការថ្វាយបង្គំគឺជាការច្រៀង លើសពីនេះទៅទៀត គេខ្វល់ខ្វាយអំពី តើ*ខ្ញុំ*ចូលចិត្តការច្រៀងនេះឬទេ ប៉ុន្តែយើងនឹងឃើញថា អ្វីដែលសំខាន់នោះមិនមែន*យើង*ចូលចិត្តការច្រៀង ឬការថ្វាយបង្គំ ឬអត់នោះទេ ប៉ុន្តែថា *ព្រះ*សព្វព្រះហឫទ័យនឹងការថ្វាយបង្គំ ឬអត់វិញ។ សូមអានខគម្ពីរដូចតទៅនេះៈ

ជនគណនា ១៥:៧; ហូសេ ៨:១៣, ៩:៨; អេម៉ុស ៥:២១-២៣; មីកា ៦:៧-៨; ម៉ាឡាគី ១:៨-១៤, ៣:៣-៤; យ៉ូហាន ៤:២៣-២៤; រ៉ូម ១២:១-២; ហេព្រើរ ១០:៦-៨, ១៣:១៥-១៦; ១ពេត្រុស ២:៥

ផ្ទៃរឿងនៅក្នុងបទគម្ពីរទាំងនេះ គឺជាការថ្វាយបង្គំ ដង្វាយ និងយញ្ញបូជាដែលព្រះសព្វព្រះហឫទ័យទទួលយក ឬព្រះមិនសព្វព្រះហឫទ័យទទួលយក។ ការថ្វាយបង្គំដែលព្រះសព្វហឫទ័យទទួលយក មិនគ្រាន់តែជាការថ្វាយបង្គំព្រះដ៏ពិតនោះទេ ប៉ុន្តែជាការថ្វាយបង្គំទ្រង់នៅក្នុងរបៀបដែលធ្វើតាមព្រះ បន្ទូលរបស់ទ្រង់នៅក្នុងជីវិតទាំងមូលរបស់យើង។ មានរបៀបខ្លះៗដែលមនុស្សបរាជ័យក្នុងការថ្វាយបង្គំបែបនេះ ។ របៀបមួយគឺថា ពួកគេគ្រាន់តែធ្វើតាមព្រះបន្ទូលរបស់ព្រះខ្លះ ប៉ុន្តែព្រងើយកន្តើយ ឬបដិសេធផ្នែកខ្លះៗទៀត។ របៀបនេះជារឿយៗបានកើតឡើងនៅក្នុងអ៊ីស្រាអែល។ ពួកគេបានរក្សាច្បាប់អំពីយញ្ញបូជា និងពិធីបុណ្យសាសនា ប៉ុន្តែពួកគេមិនបានធ្វើតាមព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតរបស់ពួកគេនោះទេ។ ពួកគេមានភាពអសីលធម៌ផ្លូវភេទ លោភលន់ ថ្វាយបង្គំរូបព្រះ...ល។ ពួកគេបានគិតថា ព្រះនឹងសព្វព្រះទ័យដោយព្រោះពួកគេបានថ្វាយយញ្ញបូជា និងធ្វើពិធីបុណ្យសាសនា ប៉ុន្តែបទគម្ពីរទាំងប៉ុន្មានខាងលើបង្ហាញថា ទ្រង់មិនសព្វព្រះទ័យទេ ហើយថា ទ្រង់ចង់ឲ្យពួកគេបញ្ឈប់ពិធីបុណ្យសាសនា ហើយបិទព្រះវិហារទៅ។ របៀបមួយទៀតដែលមនុស្សថ្វាយបង្គំព្រះនៅក្នុងរបៀបដែលព្រះមិនសព្វព្រះទ័យគឺ ពួកគេបដិសេធ ឬព្រងើយកន្តើយចំពោះព្រះបន្ទូលរបស់ព្រះ ហើយ

គ្រាន់តែថ្វាយបង្គំនៅក្នុងរបៀបដែលពួកគេចង់បានប៉ុណ្ណោះ។ នៅក្នុងចោទិយកថា ១២:៤-៦ ព្រះព្រមានអ៊ីស្រាអែលមិនឲ្យថ្វាយបង្គំព្រះតាមរបៀបរបស់ពួកសាសន៍ដទៃដែលនៅជុំវិញពួកគេនោះឡើយ។ ពួកគេមិនអាចនិយាយថា យើងកំពុងថ្វាយបង្គំព្រះយេហូវ៉ាដែលជាព្រះដ៏ពិត ប៉ុន្តែតាមរបៀបរបស់ពួកសាសន៍ដទៃបានឡើយ។ ព្រះមិនទទួលយកការថ្វាយបង្គំបែបនេះឡើយ។ ពួកគេត្រូវតែថ្វាយបង្គំ នាំយកដង្វាយ និងយញ្ញបូជាទៅកាន់កន្លែងដែលព្រះបានជ្រើសយក។ ក្រោយមកទៀត ទ្រង់បានជ្រើសយកយេរូសាឡិម ដូច្នេះពួកគេត្រូវតែនាំយកដង្វាយនិងយញ្ញបូជារបស់គេទៅកាន់យេរូសាឡឹម។ ដូច្នេះ នៅពេលពួកគេថ្វាយដង្វាយ និងយញ្ញបូជានៅទីខ្ពស់ ក៏ព្រះមិនទទួលយកដែរ ទោះបីជាពួកគេនិយាយថា ពួកគេកំពុងថ្វាយដង្វាយទៅកាន់ព្រះយ៉ាវ៉េក៏ដោយ។ ម្តងទៀត គោលការណ៍គឺ អ្វីដែលសំខាន់នោះគឺថា ការថ្វាយបង្គំដែលព្រះសព្វព្រះហឫទ័យទទួលយកបាន ហើយបើសិនការថ្វាយបង្គំនោះធ្វើតាមព្រះបន្ទូលទ្រង់ នោះទ្រង់ពិតជាសព្វព្រះហឫទ័យទទួលយក។

បញ្ហារបស់យើងគឺថា យើងទាំងអស់គ្នាមិនបានស្តាប់បង្គាប់ព្រះឡើយ។ យើងទាំងអស់គ្នាមិនគ្រាន់តែមានបាបប៉ុណ្ណោះទេ ប៉ុន្តែយើងមាននិស្ស័យបាប ហើយអស់អ្នកដែលនិស្ស័យបាបគ្រប់គ្រងលើ មិនអាចផ្គាប់ព្រះហឫទ័យព្រះបានទេ (រ៉ូម ៨:៨)។ ដូច្នេះ តើឲ្យព្រះទទួលយកយើងនិងការថ្វាយបង្គំរបស់យើងយ៉ាងដូចម្តេចទៅ?

**ព្រះយេស៊ូវ គឺជាអ្នកថ្វាយបង្គំដ៏ពិតប្រាកដដែលផ្គាប់ព្រះហឫទ័យព្រះ។** ព្រះមិនបានសព្វព្រះហឫទ័យនឹងអ៊ីស្រាអែលដោយព្រោះពួកគេមិនបានធ្វើតាមអ្វីដែលព្រះបានបង្គាប់ឲ្យពួកគេធ្វើតាមរយៈព្រះបន្ទូលរបស់ទ្រង់។ ពួកគេមិនបានថ្វាយបង្គំដោយសេចក្តីពិតនោះទេ។ ប៉ុន្តែ អំពីព្រះយេស៊ូវនោះព្រះមានបន្ទូលថា «នេះជាកូនស្ងួនភ្ងារបស់អញ ជាទីពេញចិត្តអញណាស់» (ម៉ាថាយ ៣:១៧)។ ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់ធ្វើតាមអ្វីដែលផ្គាប់ព្រះហឫទ័យព្រះវរបិតា (យ៉ូហាន ៨:២៩)។

**យើងត្រឡប់ជាអ្នកថ្វាយបង្គំដ៏ពិតប្រាកដតាមរយៈព្រះយេស៊ូវ។** ឥឡូវនេះយើងត្រឡប់ជាអ្នកថ្វាយបង្គំពិតប្រាកដដោយការទទួលយកព្រះយេស៊ូវ ពីព្រោះនៅពេលយើងទទួលយកទ្រង់ ព្រះបានអត់ទោសយើង និងរាប់យើងជាសុចរិត យើងទទួលយកសេចក្តីពិត ហើយទទួលស្គាល់ថា ព្រះគឺជាសេចក្តីពិត (យ៉ូហាន ៣:៣៣) ហើយព្រះទទួលយក «ដង្វាយ» របស់យើងតាមរយៈព្រះយេស៊ូវគ្រីស្ទ (១ពេត្រុស ២:៥)។ តាមរយៈព្រះយេស៊ូវយើងទទួលបានព្រះវិញ្ញាណបរិសុទ្ធដើម្បីឲ្យយើងអាចថ្វាយបង្គំដោយព្រះវិញ្ញាណ និងសេចក្តីពិត ដែលជាអ្វីដែលព្រះវរបិតាស្វែងរក (យ៉ូហាន ៤:២៣-២៤)។ ព្រះយេស៊ូវ ក៏បានមានបន្ទូលថា «សូមញែកគេ ចេញជាបរិសុទ្ធ ដោយសារសេចក្តីពិតរបស់ទ្រង់ ឯសេចក្តីពិតគឺជាព្រះបន្ទូលរបស់ទ្រង់» (យ៉ូហាន ១៧:១៧)។ ដូច្នេះម្តងទៀត ថ្វាយបង្គំដោយសេចក្តីពិតមានន័យថា យើងថ្វាយបង្គំទៅតាមព្រះបន្ទូលរបស់ព្រះ ពីព្រោះព្រះបន្ទូលរបស់ទ្រង់ គឺជាសេចក្តីពិត។

សកម្មភាពថ្វាយបង្គំរបស់យើង គឺជាការឆ្លើយតបចំពោះសេចក្តីមេត្តាករុណារបស់ព្រះដែលទ្រង់បានប្រទានឲ្យយើងតាមរយៈព្រះគ្រីស្ទ។ យើងត្រូវតែចងចាំថារ៉ូម ១២:១-២ មានបន្ទាប់ពីអ្វីដែលលោកប៉ុលបានសរសេរនៅក្នុងគម្ពីររ៉ូមជំពូក ១-១១។ សូមកុំបំបែករ៉ូម ១២:១-២ ចេញពីរ៉ូម ១-១១។ នៅក្នុងរ៉ូម ១-១១ លោកប៉ុលពន្យល់អំពីដំណឹងល្អដែលបង្ហាញពីសេចក្តីមេត្តាករុណាដ៏ធំធេងរបស់ព្រះមកកាន់យើងតាមរយៈព្រះគ្រីស្ទ ដែលយើងទទួលបានដោយយើងជឿលើព្រះគ្រីស្ទ។ បន្ទាប់មកប៉ុលសរសេរថា «ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយសេចក្តីមេត្តាករុណានៃព្រះ ឱ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង កុំឱ្យត្រាប់តាមសម័យនេះឡើយ ចូរឱ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចមើល ឱ្យបាន

ស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អស្រួលទទួល ហើយគ្រប់លក្ខណ៍ផង» (រ៉ូម ១២:១-២)។ ដូច្នេះ ចូរកត់សំគាល់ថា ការថ្វាយរូបកាយរបស់យើងគឺជាឆ្លើយតបទៅចំពោះសេចក្ដីមេត្តាករុណារបស់ព្រះដែលទ្រង់ប្រទានឲ្យយើងតាមរយៈព្រះគ្រីស្ទ។

## អ្វីដែលមនុស្សធ្វើដើម្បីថ្វាយបង្គំព្រះមានការផ្លាស់ប្ដូរតាមកំឡុងពេលខុសៗគ្នានៅក្នុងព្រះគម្ពីរ

អ្វីដែលរាស្ត្ររបស់ព្រះធ្វើដើម្បីថ្វាយបង្គំទ្រង់មានការផ្លាស់ប្ដូរតាមកំឡុងពេលខុសៗគ្នានៅក្នុងព្រះគម្ពីរ។ ទោះយ៉ាងណា មានធាតុខ្ជាប់ខ្ជួនខ្លះដែលយើងបានមើលឃើញខាងលើ។ ជាឧទាហរណ៍ ការថ្វាយបង្គំពិតប្រាកដ តែងតែជាការឆ្លើយតបចំពោះការបើកសំដែងរបស់ព្រះ ជាការឆ្លើយតបចំពោះព្រះបន្ទូលរបស់ព្រះ។ ទាក់ទងនឹងចំនុចនេះ ការថ្វាយបង្គំដែលព្រះសព្វព្រះហឫទ័យនិងទទួលយក ត្រូវតែ និងតែងតែមកពីជំនឿ ពីព្រោះយើងមិនអាចផ្គាប់ព្រះហឫទ័យព្រះបានដោយគ្មានជំនឿបានឡើយ (ហេព្រើរ ១១:៦)។ ម្ដងទៀត ជំនឿដ៏ពិតគឺជាការឆ្លើយតបចំពោះព្រះបន្ទូលរបស់ព្រះ។ ជាឧទាហរណ៍ មូលហេតុដែលអ័ប្រាហាំអាចមានជំនឿបានគឺថា គាត់បានទទួលព្រះបន្ទូលរបស់ព្រះហើយអ័ប្រាហាំបានជឿព្រះបន្ទូលនោះ។ ប៉ុន្តែព្រះបន្ទូលដែលយើងជឿ និងដើរតាមមានការផ្លាស់ប្ដូរនៅក្នុងសម័យផ្សេងៗក្នុងខ្សែរឿងរបស់ព្រះគម្ពីរ។

### អ័ដាមនិងអេវ៉ានៅក្នុងសួនច្បារអេដែន (ទីបរិសុទ្ធរបស់ព្រះ)។

នៅក្នុងសួនច្បារអេដែនអ័ដាមបានទទួលព្រះបន្ទូលរបស់ព្រះដែលគាត់ត្រូវតែធ្វើការ មើលថែរក្សា និងការពារសួនច្បារ។ សកម្មភាពថ្វាយបង្គំរបស់គាត់គឺត្រូវតែស្ដាប់បង្គាប់ព្រះបន្ទូលនោះដោយការបំរើព្រះនៅក្នុងសួនច្បារ។ នៅពេលគាត់និងប្រពន្ធរបស់គាត់បានមិនស្ដាប់បង្គាប់គឺជាភាពបរាជ័យមួយក្នុងការដែលពួកគេគួរតែបំរើ ស្ដាប់បង្គាប់ និងថ្វាយបង្គំព្រះ។

### អ៊ីស្រាអែលនៅក្នុងទឹកដីសន្យា (ទីបរិសុទ្ធថ្មីរបស់ព្រះ)

អ៊ីស្រាអែលបានទទួលក្រឹត្យវិន័យ ដែលបានពន្យល់អំពីរបៀបដែលពួកគេត្រូវតែថ្វាយបង្គំព្រះនៅក្នុងទឹកដីសន្យា។ ក្រឹត្យវិន័យបានរួមបញ្ចូលទាំងច្បាប់ដែលទាក់ទងនឹងសីលធម៌ ការងារជាសង្ឃ ព្រះវិហារ ដង្វាយ និងយញ្ញបូជា...ល។ ពួកគេថ្វាយបង្គំព្រះដោយស្ដាប់បង្គាប់ក្រិត្យវិន័យទាំងនោះ។ យើងបានឃើញខាងលើថា ចោទិយកថា ១២ កត់ត្រាសេចក្ដីបង្គាប់របស់ព្រះថា ពួកគេត្រូវតែនាំយកដង្វាយទៅកាន់កន្លែងដែលព្រះបានជ្រើសយក ដែលទីបំផុតជាយេរូសាឡឹម។

### ព្រះយេស៊ូវ និងសម្ព័ន្ធមេត្រីថ្មី

ទោះយ៉ាងណា អ្វីដែលយើងធ្វើដើម្បីថ្វាយបង្គំ ព្រះបានផ្លាស់ប្ដូរទាំងស្រុងដោយព្រោះព្រះយេស៊ូវបានយាងមក ប៉ុន្តែការថ្វាយបង្គំនៅតែស្ថិតក្រោមគោលការណ៍ដូចដែលយើងបានកត់សំគាល់ខាងលើដដែល។ ខាងក្រោមនេះយើងនឹងកត់សំគាល់លើការផ្លាស់ប្ដូរខ្លះ។

១. ការផ្លាស់ប្ដូរធំមួយគឺថា ឥឡូវនេះការថ្វាយបង្គំរបស់យើងពាក់ព័ន្ធនឹងព្រះត្រៃឯក។ ព្រះយេស៊ូវបានមានបន្ទូលថា «ដើម្បីឱ្យមនុស្សទាំងអស់បានគោរពប្រតិបត្តិដល់ព្រះរាជបុត្រា ដូចជាគោរពប្រតិបត្តិដល់ព្រះវរបិតាដែរ អ្នកណាដែលមិន គោរពប្រតិបត្តិដល់ព្រះរាជបុត្រា នោះក៏មិនគោរព ប្រតិបត្តិដល់ព្រះវរបិតា ដែលចាត់ឱ្យទ្រង់មកដែរ» (យ៉ូហាន ៥:២៣)។ យើងមើលឃើញនៅក្នុងព្រះគម្ពីរសញ្ញាថ្មីថាមនុស្សបានថ្វាយបង្គំព្រះយេស៊ូវ (ឧទាហរណ៍ លូកា ២៤:៥២; យ៉ូហាន ៩:៣៨; វិវរណៈ ៥:៨-១៤)

២. ទីកន្លែង។ ជារឿយៗពួកគ្រីស្ទបរិស័ទមិនដឹងអំពីសារៈសំខាន់នៃចោទិយកថា ១២ ដើម្បីឲ្យយល់ការសន្ទនារបស់ព្រះយេស៊ូវជាមួយនឹងស្ត្រីសាសន៍សាម៉ារីនោះទេ។ សូមចងចាំថា ព្រះបានមានបន្ទូលនៅក្នុងចោទិយកថា ១២ ថា ជនជាតិអ៊ីស្រាអែលត្រូវតែថ្វាយបង្គំ និងនាំដង្វាយ និងយញ្ញបូជារបស់ខ្លួនមកក្នុងយេរូសាឡឹម។ បន្ទាប់ពីរាជ្យស្ដេចសាឡូម៉ូន អ៊ីស្រាអែលត្រូវចែកជាពីរ ហើយសាម៉ារីបានក្លាយជារាជធានីនៃអាណាចក្រខាងជើង ហើយយេរូសាឡឹមក្លាយជារាជធានីនៃអាណាចក្រខាងត្បូង ដែលហៅថាយូដា។ មនុស្សនៃអាណាចក្រខាងជើង ដែលមានសាម៉ារីជារាជធានី មិនចង់ទៅឯយេរូសាឡឹមដើម្បីថ្វាយបង្គំនោះទេ ដូច្នេះពួកគេបានបង្កើតកន្លែងផ្សេងៗទៀតនៅក្នុងអាណាចក្រខាងជើង ដែលពួកគេអាចថ្វាយបង្គំបាន។ ការនេះបាននាំឲ្យមានការពិភាក្សាអស់ជាច្រើនសតវត្សរវាងពួកយូដានិងមនុស្សមកពីអាណាចក្រខាងជើង (រួមទាំងសាសន៍សាម៉ារី) អំពីទីកន្លែងដែលពួកគេគួរតែថ្វាយបង្គំ។ ពួកយូដាអាចសំអាងលើចោទិយកថា ១២ និងព្រះវិហារនៅក្នុងយេរូសាឡឹម ហើយនិយាយថា យើងត្រូវតែថ្វាយបង្គំនៅក្នុងយេរូសាឡឹម។ ដោយព្រោះការនេះគឺជាការពិភាក្សាធំដែលពួកយូដានិងសាសន៍សាម៉ារីមានជំលោះអស់ជាច្រើនសតវត្ស នោះវាជាបញ្ហាដែលស្ត្រីសាសន៍សាម៉ារីលើកឡើងក្នុងការសន្ទនាជាមួយព្រះយេស៊ូវ នៅពេលគាត់ដឹងថាទ្រង់គឺជាហោរាម្នាក់ (យ៉ូហាន ៤:១៩-២០)។ ចម្លើយរបស់ព្រះគឺអស្ចារ្យណាស់។ ជារឿយៗយើងមិនដឹងថាចំលើយរបស់ព្រះយេស៊ូវអស្ចារ្យប៉ុណ្ណានោះទេ។ ទ្រង់ឆ្លើយនៅក្នុង ៤:២១-២៤ ថា ទ្រង់កំពុងនាំសម័យថ្មីមកដល់ ខណៈដែលចោទិយកថា ១២ លែងត្រូវការការស្ដាប់បង្គាប់តាមទៀតហើយ។ ព្រះវិហារដែលជាទីកណ្ដាលនៃការថ្វាយបង្គំរបស់អ៊ីស្រាអែល លែងចាំបាច់ទៀតហើយ។ ឥឡូវនេះទីកន្លែងថ្វាយបង្គំមិនសំខាន់ទេ ប៉ុន្តែអ្វីដែលសំខាន់គឺថា យើងថ្វាយបង្គំដោយព្រះវិញ្ញាណនិងសេចក្ដីពិតវិញ។ មានតែអស់អ្នកដែលទទួលយកព្រះយេស៊ូវប៉ុណ្ណោះដែលអាចថ្វាយបង្គំបែបនេះបាន ពីព្រោះមានតែអស់អ្នកដែលទទួលយកព្រះយេស៊ូវប៉ុណ្ណោះដែលមានព្រះវិញ្ញាណ។

៣. ពួកសង្ឃនិងយញ្ញបូជា។ ពួកសង្ឃនិងយញ្ញបូជាគឺចំនុចកណ្ដាលនៃការថ្វាយបង្គំនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ប៉ុន្តែបើសិនព្រះវិហារលែងចាំបាច់ទៀត នោះតើពួកសង្ឃ និងយញ្ញបូជាលែងចាំបាច់ទៀតដែរឬទេ? ដោយសារតែជីវិតការសុគត ការរស់ឡើងវិញ និងការយាងត្រឡប់ទៅស្ថានសួគ៌របស់ព្រះយេស៊ូវ ពួកសង្ឃ និងយញ្ញបូជាលែងចាំបាច់ទៀតហើយ។ កណ្ឌគម្ពីរហេព្រើរបង្រៀនថា ព្រះយេស៊ូវបំពេញសំរេចការងារទាំងអស់នេះហើយ។ ទ្រង់គឺជាសម្ដេចសង្ឃរបស់យើង ដែលបានថ្វាយអង្គទ្រង់ជាយញ្ញបូជាឥតខ្ចោះជំនួសអំពើបាបរបស់យើង។ ដូច្នេះ ការងារជាសង្ឃមានការផ្លាស់ប្រែទៅ (ហេព្រើរ ៧:១២) ហើយសេចក្ដីបញ្ញត្តដែលមានពីមុនត្រូវលើកចោលវិញ (ហេព្រើរ ៧:១៨)។ ការផ្លាស់ប្ដូរនេះមានន័យថា សារដំណឹងល្អនៃការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវផ្លាស់ប្ដូរអ្វីដែលយើងធ្វើដើម្បីថ្វាយបង្គំព្រះ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ការថ្វាយបង្គំជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយព្រះវិហារ ពួកសង្ឃដង្វាយ និងយញ្ញបូជា។ សូមស្រមៃស្រម៉ៃថា អ្នកជាសាសន៍យូដាម្នាក់នៅក្នុងសតវត្សទីមួយដែលក្លាយជាគ្រីស្ទបរិស័ទម្នាក់។ ប្រជាជនរបស់អ្នកបានថ្វាយបង្គំព្រះតាមរយៈពួកសង្ឃ និងការថ្វាយដង្វាយ និងយញ្ញបូជា។ ឥឡូវគេបានប្រាប់អ្នកថា យើងលែងថ្វាយបង្គំព្រះតាមរបៀបនេះទៀតហើយ។ តើអ្នកគិតយ៉ាងដូចម្ដេច? អ្នកនឹងសួរថា អញ្ចឹងតើយើងថ្វាយបង្គំព្រះដោយរបៀបយ៉ាងដូចម្ដេចទៅ? មានចម្លើយនៅក្នុង រ៉ូម ១២:១; ហេព្រើរ ១៣:១៥; ១ពេត្រុស ២:៤។ តើហេតុអ្វីប៉ុលនិយាយថា «យញ្ញបូជារស់» នៅក្នុងរ៉ូម ១២:១? ពីព្រោះពួកគេមានទំលាប់សំឡាប់យញ្ញបូជាដែលគេថ្វាយ។ ប៉ុន្តែឥឡូវនេះ ជំនួសឲ្យការនាំសត្វទៅថ្វាយព្រះហើយ*សម្លាប់*សត្វនោះ យើងនាំយកជីវិតរបស់យើងផ្ទាល់ទៅថ្វាយព្រះ និងថ្វាយរូបកាយរបស់យើងជាយញ្ញបូជា*រស់* ដោយសារតែសេចក្ដីមេត្តាករុណារបស់ព្រះនៅក្នុងការសង្គ្រោះយើងតាមរយៈព្រះយេស៊ូវវិញ។ យើងមិនថ្វាយយញ្ញបូជាខាងសាច់ឈាមទេ (សត្វ...ល) ប៉ុន្តែយើងថ្វាយយញ្ញបូជាខាងវិញ្ញាណវិញ (១ពេត្រុស ២:៤)។ យើងថ្វាយការសរសើរ និងប្រកាសអំពីព្រះនាមរបស់ព្រះយេស៊ូវ (ហេព្រើរ ១៣:១៥)។ សូមកត់សំគាល់ថា នៅក្នុងខគម្ពីរទាំងនេះ អ្នកនិពន្ធថ្លែងថា ព្រះសព្វព្រះហឫទ័យ និងទទួល

យកការថ្វាយបង្គំបែបនេះ។ យើងមិនមានពួកសង្ឃដូចនៅក្នុងព្រះគម្ពីរសញ្ញាចាស់ទៀតទេ ប៉ុន្តែគ្រីស្ទបរិស័ទទាំងអស់គឺជា «ពួកសង្ឃ» ហើយព្រះគ្រីស្ទ គឺជាសម្ដេចសង្ឃរបស់យើងរាល់គ្នា។

លើសពីនេះ លោកប៉ុលសរសេរនៅក្នុងរ៉ូម ១:៩ ថា «ព្រះដែលខ្ញុំបំរើដោយវិញ្ញាណខ្ញុំ ក្នុងដំណឹងល្អពីព្រះរាជបុត្រាទ្រង់»។ ពាក្យ «បំរើ» នៅទីនេះគឺជាពាក្យដែលត្រូវបានបកប្រែជាការថ្វាយបង្គំផងដែរ។ របៀបដែលលោកប៉ុលថ្វាយបង្គំព្រះមិនមែនជាការថ្វាយយញ្ញបូជាទេ ប៉ុន្តែដោយការប្រកាសដំណឹងល្អវិញ។ ដូច្នេះ ការអធិប្បាយគឺជាសកម្មភាពថ្វាយបង្គំមួយ។ ដូច្នេះ ជាការខុសក្នុងការនិយាយថា ពេលវេលាច្រៀងនៅក្នុងពួកជំនុំ គឺជាការថ្វាយបង្គំ ប៉ុន្តែមិននិយាយថា សេចក្ដីអធិប្បាយ គឺជាការថ្វាយបង្គំនោះ។ ការអធិប្បាយ គឺជាសកម្មភាពថ្វាយបង្គំដោយអ្នកអធិប្បាយ។ អស់អ្នកដែលស្ដាប់ឮព្រះបន្ទូលរបស់ព្រះ បានស្ដាប់ឮព្រះបន្ទូលដែលដឹកនាំពួកគេឲ្យថ្វាយបង្គំព្រះបានក្នុងរបៀបដែលព្រះសព្វព្រះហឫទ័យ ដោយគេរីកចម្រើននៅក្នុងការយល់ដឹងអំពីព្រះ សេចក្ដីស្រលាញ់របស់ទ្រង់សំរាប់យើងដែលឃើញនៅក្នុងព្រះគ្រីស្ទ និងបំណងព្រះហឫទ័យទ្រង់សំរាប់យើង ដែលទាំងអស់តាមរយៈការរៀនព្រះគម្ពីរ។ នៅក្នុងរបៀបនេះ អ្នកអធិប្បាយគឺជា «អ្នកដឹកនាំថ្វាយបង្គំ» ម្នាក់ ពីព្រោះគាត់កំពុងដឹកនាំមនុស្សទៅកាន់ព្រះ និងថ្វាយបង្គំព្រះតាមរបៀបដែលគាប់ព្រះហឫទ័យទ្រង់។

លើសពីនេះ លោកប៉ុលនិយាយថា ការអធិប្បាយដំណឹងល្អមិនគ្រាន់តែជាសកម្មភាពបំរើព្រះ ថ្វាយបង្គំព្រះប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកាតព្វកិច្ចបែបពួកសង្ឃផងដែរ (រ៉ូម ១៥:១៥-១៦)។ ដូច្នេះ អ្វីដែលពួកសង្ឃមានន័យសំរាប់យើងផ្លាស់ប្ដូរពីព្រះគម្ពីរសញ្ញាចាស់។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពួកសង្ឃបានថ្វាយបង្គំដោយការថ្វាយយញ្ញបូជា និងដង្វាយទៅតាមក្រឹត្យវិន័យ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី លោកប៉ុលនិយាយថា គាត់ថ្វាយបង្គំព្រះដោយការប្រកាសអំពីព្រះយេស៊ូវ ដែលជាយញ្ញបូជាពិតតែមួយដែលព្រះអាចទទួលយកបាន។ លោកប៉ុលមិនថ្វាយយញ្ញបូជាទេ ប៉ុន្តែតាមរយៈការប្រកាសដំណឹងល្អដែលពួកសាសន៍ដទៃអាចជាដង្វាយដែលព្រះទទួលយកបាន។ ម្ដងទៀត បទគម្ពីរនេះបង្ហាញថា យើងត្រឡប់ជាដង្វាយដែលព្រះទទួលយកបានតាមរយៈព្រះយេស៊ូវ ហើយយើងបរិសុទ្ធតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។

## កុំត្រឡប់ទៅកាន់ព្រះគម្ពីរសញ្ញាចាស់

ដូច្នេះ ជាការសំខាន់ដែលយើងមិនត្រឡប់ទៅកាន់របៀបថ្វាយបង្គំនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពីព្រោះរបៀបនោះដូចជាការបដិសេធព្រះយេស៊ូវដែរ។ នេះគឺជាសេចក្ដីល្បួងមួយដែលពួកគ្រីស្ទបរិស័ទដែលជាសាសន៍យូដាបានប្រឈមនៅក្នុងសតវត្សទីមួយ ហើយកណ្ឌគម្ពីរហេព្រើរលើកទឹកចិត្តឲ្យពួកគេកុំត្រឡប់ទៅតាមរបៀបចាស់នោះវិញ។ នេះគឺជាកំហុសមួយដែលពួកជំនុំរ៉ូម៉ាំងកាតូលិកបានប្រព្រឹត្ត។ នៅក្នុងប្រវត្តិសាស្ត្រ ពួកជំនុំរ៉ូម៉ាំងកាតូលិកបានអភិវឌ្ឍ ប្រព័ន្ធមួយដែលពួកគេមានពួកសង្ឃដែលថ្វាយយញ្ញបូជាជំនួសឲ្យបណ្ដាជនដូចនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែរ។ នេះគឺជាមូលហេតុមួយដែលពួកគេបានធ្វើកម្មវិធីថ្វាយបង្គំនៅក្នុងជំនុំជាភាសាដែលមនុស្សមិនយល់។ ពួកគេបានជឿថា តួនាទីរបស់អ្នកដឹកនាំគឺជាសង្ឃថ្វាយយញ្ញបូជាហើយសកម្មភាពនោះសំខាន់ជាងការអធិប្បាយ។ នៅក្នុងកំណែទំរង់សេចក្ដីជំនឿ ពួកអ្នកកំណែទំរង់បានយល់យ៉ាងច្បាស់ថា នៅក្នុងព្រះគម្ពីរសញ្ញាថ្មីពួកអ្នកដឹកនាំមិនមែនជាពួកសង្ឃដែលថ្វាយយញ្ញបូជាជំនួសឲ្យមនុស្សនោះទេ ប៉ុន្តែតួនាទីរបស់ពួកគេគឺត្រូវអធិប្បាយអំពីព្រះគ្រីស្ទដើម្បីឲ្យពួកគេបានដឹកនាំមនុស្សឲ្យទុកចិត្តលើទ្រង់។ នៅក្នុងរបៀបនេះ មនុស្សដែលទទួលយកព្រះយេស៊ូវត្រឡប់ជាដង្វាយដែលព្រះទទួលយក។ ដូច្នេះ ការងារជាសង្ឃរបស់អស់ពួកអ្នកជឿគឺជាសេចក្ដីពិតសំខាន់មួយដែលពួកអ្នកកំណែទំរង់បានប្រកាស។

## ការអនុវត្ត

១. សូមសញ្ជឹងគិតលើ ការសិក្សា និងមានអំណរនៅក្នុងឧត្តមភាពរបស់ព្រះ។ ការធ្វើដូចនេះជួយយើងឲ្យមើលឃើញថា ទ្រង់សមនឹងទទួលបានការថ្វាយបង្គំ។

២. យើងមិនគួរគិតថា ការថ្វាយបង្គំគ្រាន់តែជាសកម្មភាពមួយនៅថ្ងៃអាទិត្យនៅពួកជំនុំនោះឡើយ។ នៅពេលយើងគិតអំពីពួកជំនុំ យើងមិនគួរគិតថា ការថ្វាយបង្គំគ្រាន់តែជាការច្រៀងប៉ុណ្ណោះឡើយ។ គ្មានហេតុផលតាមព្រះគម្ពីរដែលនាំឲ្យយើងគិតថា អ្នកដឹកនាំចម្រៀងគឺជា «អ្នកដឹកនាំថ្វាយបង្គំ» លើសជាងអ្នកអធិប្បាយគឺជា «អ្នកដឹកនាំថ្វាយបង្គំ» (ឬអ្នកដឹកនាំពួកជំនុំអធិស្ឋានគឺជា «អ្នកដឹកនាំថ្វាយបង្គំ») នោះឡើយ។ ជីវិតទាំងស្រុងរបស់យើងគឺជាសកម្មភាពថ្វាយបង្គំ ពីព្រោះយើងបំរើព្រះរៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់យើង។ ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរ ធ្វើទាំងអស់សំរាប់ចម្រើនសិរីល្អដល់ព្រះចុះ (១កូរិនថូស ១០:៣១) ហើយក្នុងគ្រប់ការទាំងអស់ ទោះបើការអ្វីដែលអ្នករាល់គ្នានឹងធ្វើដោយពាក្យសំដី ឬកិរិយាក៏ដោយ ចូរធ្វើទាំងអស់ ដោយព្រះនាមនៃព្រះអម្ចាស់យេស៊ូវ (កូល៉ុស ៣:១៧)។ យើងត្រូវតែថ្វាយជីវិតទាំងស្រុងរបស់យើងជាយញ្ញបូជារស់ ហើយសកម្មភាពនៃការបំរើព្រះទាំងអស់ជារៀងរាល់ថ្ងៃ គឺជាការថ្វាយបង្គំ។ ការធ្វើជាឪពុកល្អ ឬជាម្តាយល្អ ឬជាកូនល្អគឺជាសកម្មភាពថ្វាយបង្គំមួយ។ ការប្រកាសដំណឹងល្អរបស់ព្រះយេស៊ូវ គឺជាការថ្វាយបង្គំ។ ការស្រលាញ់អ្នកជិតខាងរបស់យើង គឺជាការថ្វាយបង្គំ និងការនាំមនុស្សឲ្យសរសើរតម្កើងព្រះ។

៣. នៅក្នុងព្រះគម្ពីរសញ្ញាថ្មីគ្មានកន្លែងណានិយាយថា យើងទៅព្រះវិហារ(ពួកជំនុំ)ដើម្បីថ្វាយបង្គំនោះទេ ប៉ុន្តែជីវិតទាំងស្រុងរបស់យើងគឺជាការថ្វាយបង្គំ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីគ្មានកន្លែងណានិយាយថា ការប្រជុំថ្ងៃអាទិត្យ គឺជាកម្មវិធីថ្វាយបង្គំនោះទេ។ នៅពេលគ្រីស្ទបរិស័ទខ្លះឮដូច្នេះ ពួកគេសួរថា «អញ្ចឹងហេតុអ្វីទៅព្រះវិហារ?»។ យើងក៏ថ្វាយបង្គំនៅឯព្រះវិហារផងដែរ ប៉ុន្តែកម្មវិធីទាំងមូលនៃពួកជំនុំ គឺជាសកម្មភាពថ្វាយបង្គំ (រួមទាំងការច្រៀង ការអធិស្ឋាន ការអធិប្បាយ...ល) ហើយពួកជំនុំគឺជាការថ្វាយបង្គំជាក្រុម ក៏សំខាន់ផងដែរនៅក្នុងព្រះគម្ពីរ។

៤. នៅពេលយើងគិតអំពីការថ្វាយបង្គំ ការដែលយើងចូលចិត្ត ឬមិនចូលចិត្តមិនមែនជារឿងសំខាន់បំផុតនោះទេ ប៉ុន្តែសំខាន់បំផុតនោះគឺថា ព្រះសព្វព្រះទ័យចំពោះការថ្វាយបង្គំ ឬអត់វិញ។ ដូច្នេះ យើងគួរតែសួរថា តើជីវិតរបស់យើងផ្គាប់ព្រះហឫទ័យព្រះឬទេ? តើការថ្វាយបង្គំផ្ទាល់ខ្លួនរបស់យើងផ្គាប់ព្រះហឫទ័យព្រះដែរឬទេ? យើងក៏គួរតែសួរថា តើកម្មវិធីថ្វាយបង្គំរបស់ពួកជំនុំរបស់យើងផ្គាប់ព្រះហឫទ័យព្រះដែរឬទេ? ជារឿយៗពួកគ្រីស្ទបរិស័ទយល់ខុសចំពោះការថ្វាយបង្គំ ហើយគ្រាន់តែខ្វល់ខ្វាយថា តើពួកគេចូលចិត្ត ឬមិនចូលចិត្តការថ្វាយបង្គំ។ លើសពីនេះ ពួកគេគិតថា ការថ្វាយបង្គំគ្រាន់តែជាការច្រៀង អញ្ចឹងពួកគេអាចនិយាយថា «ការថ្វាយបង្គំនៅពួកជំនុំនេះល្អ» ពីព្រោះពួកគេគិតថាការច្រៀង និងភ្លេងពីរោះ ឬថា «ការថ្វាយបង្គំនៅពួកជំនុំនោះអន់» ពីព្រោះការច្រៀង និងភ្លេងមិនពិរោះសោះ។ ការគិតបែបនេះពិតជាមិនតាមព្រះគម្ពីរនោះឡើយ (ប៉ុន្តែយើងគួរតែព្យាយាមធ្វើឲ្យការច្រៀង និងភ្លេងនៅក្នុងពួកជំនុំយើងបានល្អ)។ ការថ្វាយបង្គំនៅពួកជំនុំល្អ បើសិនព្រះសព្វព្រះហឫទ័យ ហើយការថ្វាយបង្គំផ្គាប់ព្រះហឫទ័យព្រះ បើសិនពួកគេកំពុងថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិត ហើយសមាជិកនីមួយៗរស់នៅតាមព្រះបន្ទូលរបស់ព្រះ។

ពេលខ្លះពួកជំនុំផ្សេងៗគិតថា ពួកគេមានការថ្វាយបង្គំល្អ ពីព្រោះមានភ្លេងពីរោះ ប៉ុន្តែពួកអ្នកដឹកនាំមិនស្មោះត្រង់ក្នុងជីវិតអាពាហ៍ពិពាហ៍ មនុស្សបានលួចប្រាក់ពីដង្វាយរបស់ពួកជំនុំ សមាជិកមានជម្លោះជាមួយគ្នា ហើយពួកអ្នកដឹកនាំមិនអធិប្បាយព្រះគម្ពីរទាំងមូល (ឧទាហរណ៍ ពួកគេមិនដែលប្រកាសអ្វីដែលព្រះមានបន្ទូលអំពីសេចក្តីក្រោធរបស់ព្រះសោះ)។ នៅក្នុងករណីទាំងនេះ បើសិនពួកជំនុំគិតថា ការថ្វាយបង្គំរបស់ពួកគេល្អ នោះពួកគេបានបញ្ឆោតខ្លួនឯងហើយ។ បើសិនពួកជំនុំពិតជាមិនទុកចិត្ត និងស្តាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះ បើសិនពួកគេមិនប្រកាសដំណឹង

ល្អពិតប្រាកដ បើសិនសមាជិកនីមួយៗ មិនស្រលាញ់គ្នាទៅវិញទៅមក បើសិនការអធិប្បាយអន់ បើសិនការអធិស្ឋានមិនល្អ នោះការថ្វាយបង្គំគឺអន់ ទោះបើពួកគេមានភ្លេង និងការច្រៀងបានពីរោះយ៉ាងណាក៏ដោយ។ ពួកជំនុំជាច្រើនបានបញ្ឆោតខ្លួនឯងតាមរបៀបនេះ។ នៅពេលយើងបន្តដូចនេះ នោះយើងអាចដូចជាអ៊ីស្រាអែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលព្រះមានបន្ទូលថាទ្រង់បានស្អប់ការថ្វាយបង្គំរបស់ពួកគេ ហើយចង់ឲ្យពួកគេបញ្ឈប់ការថ្វាយបង្គំរបស់គេ។ ព្រះយេស៊ូវបានប្រទានការព្រមានដូចគ្នានេះទៅកាន់ពួកជំនុំផ្សេងៗនៅក្នុងសំបុត្រទៅកាន់ពួកជំនុំផ្សេងៗនៅក្នុងកណ្ឌវិវរណៈជំពូក២-៣។

៥. ក្រុមគ្រួសារ គឺជាកន្លែងមួយសំរាប់ការថ្វាយបង្គំ។ ឪពុកម្តាយដែលជាគ្រីស្ទបរិស័ទត្រូវតែបង្រៀនកូនៗរបស់ខ្លួនអំពីព្រះ និងដំណឹងល្អ ក្រុមគ្រួសារអាចអានព្រះគម្ពីរជាមួយគ្នា អធិស្ឋានជាមួយគ្នាហើយថ្វាយសិរីល្អដល់ព្រះជាមួយគ្នានៅពេលពួកគេស្រលាញ់គ្នាទៅវិញទៅមក។

៦. ការអធិប្បាយ គឺសំខាន់ក្នុងការដឹកនាំក្រុមជំនុំថ្វាយបង្គំព្រះ។ ដើម្បីធ្វើដូចនេះ ការអធិប្បាយត្រូវពន្យល់ព្រះគម្ពីរ និងសរសើរតម្កើងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ពេលខ្លះការច្រៀងផ្តោតលើព្រះ (ដែលល្អ) ប៉ុន្តែការអធិប្បាយផ្តោតលើមនុស្ស (ដែលអាក្រក់)។ ជារឿយៗបទចម្រៀងថ្វាយបង្គំផ្តោតលើលក្ខណៈរបស់ព្រះ និងការងារដ៏អស្ចារ្យរបស់ព្រះ ប៉ុន្តែការអធិប្បាយមិនផ្តោតលើព្រះទេ បែរជាផ្តោតលើបញ្ហាបច្ចុប្បន្ន ហើយបញ្ហា និងទំនាក់ទំនងផ្ទាល់ខ្លួនទៅវិញ។ ការធ្វើដូចនេះជាការខុស។ លោកប៉ុលនិយាយថា យើងប្រកាសពីព្រះគ្រីស្ទ (កូល៉ុស ១:២៨)។ សេចក្តីអធិប្បាយ ត្រូវតែនាំមនុស្សឲ្យនិយាយថា «ព្រះធំអស្ចារ្យណាស់ ហើយទ្រង់សមនឹងទទួលការថ្វាយបង្គំមែន» «យើងមានសេចក្តីសង្គ្រោះដ៏ធំធេងតាមរយៈព្រះយេស៊ូវ» «ប្រាជ្ញាដ៏អស្ចារ្យរបស់ព្រះនៅក្នុងព្រះគម្ពីរនាំឲ្យយើងដឹងអំពីរបៀបស្រលាញ់និងបំរើទ្រង់»។ ដូច្នេះ ការអធិប្បាយគឺជាទំនួលខុសត្រូវធំមួយ ហើយអ្នកអធិប្បាយត្រូវខិតខំសិក្សាព្រះគម្ពីរ និងរៀបចំសេចក្តីអធិប្បាយរបស់ខ្លួនឲ្យបានល្អ។ ប៉ុន្តែគោលដៅនៃសេចក្តីអធិប្បាយមិនដើម្បីលើកតម្កើងអ្នកអធិប្បាយនោះទេ ប៉ុន្តែដើម្បីថ្វាយសិរីល្អដល់ព្រះគ្រីស្ទវិញ។ គោលដៅរបស់សេចក្តីអធិប្បាយ គឺត្រូវដឹកនាំក្រុមជំនុំឲ្យថ្វាយបង្គំព្រះនៅក្នុងជីវិតរបស់ពួកគេតាមរបៀបដែលផ្គាប់ព្រះហឫទ័យទ្រង់។ ដើម្បីជួយឲ្យពួកអ្នកអធិប្បាយអាចធ្វើដូច្នេះបាន ពួកគេមិនគួរគ្រាន់តែអានសៀវភៅអំពីអាពាហ៍ពិពាហ៍ ទំនាក់ទំនង ការងារ ការគ្រប់គ្រងជំនុំ...ល. ប៉ុន្តែពួកគេគួរតែអានសៀវភៅអំពីព្រះ និងព្រះគម្ពីរដែលជួយឲ្យពួកគេស្គាល់ព្រះកាន់តែច្បាស់ យល់អំពីឧត្តមភាពរបស់ទ្រង់ និងយល់អំពីផែនការណ៍ និងគោលបំណងរបស់ទ្រង់ដែលបានបើកសំដែងនៅក្នុងព្រះគម្ពីរ។

៧. យើងទន្ទឹងរង់ចាំការបង្កបង្កើតថ្មី ដែលជាកន្លែងដែលប្រជារាស្ត្រដែលព្រះបានប្រោសលោះហើយ នឹងថ្វាយបង្គំទ្រង់ជារៀងដរាបទៅ។

# កំណត់


១. Alexander, T. D., & Rosner, B. S. (Eds.). (2000). In *New dictionary of biblical theology*. Downers Grove, IL: InterVarsity Press.

២. Easton, M. G. (1893). In *Easton's Bible dictionary*. New York: Harper & Brothers.

៣. Ferguson, S. B., & Packer, J. I. (2000). In *New dictionary of theology*. Downers Grove, IL: InterVarsity Press.

៤. Marshall, I. H. (1996). Worship. In (D. R. W. Wood, A. R. Millard, J. I. Packer, & D. J. Wiseman, Eds.) *New Bible dictionary*. Leicester, England; Downers Grove, IL: InterVarsity Press.

## ឯកសារនិងសៀវភៅស្រាវជ្រាវ


Alexander, T. D., & Rosner, B. S. (Eds.). (2000). In *New dictionary of biblical theology*. Downers Grove, IL: InterVarsity Press.

Easton, M. G. (1893). In *Easton's Bible dictionary*. New York: Harper & Brothers.

Elwell, W. A., & Beitzel, B. J. (1988). In *Baker encyclopedia of the Bible*. Grand Rapids, MI: Baker Book House.

Ferguson, S. B., & Packer, J. I. (2000). In *New dictionary of theology*. Downers Grove, IL: InterVarsity Press.

Marshall, I. H. (1996). Worship. In (D. R. W. Wood, A. R. Millard, J. I. Packer, & D. J. Wiseman, Eds.) *New Bible dictionary*. Leicester, England; Downers Grove, IL: InterVarsity Press.

Piper, J. "Preaching as worship, meditations on Expository Exultation" (1995). *Trinity Journal*, *16*(1), 27–45.